# មេរៀនទី ៥៨៖ លោកយ៉ូហានធ្វើបុណ្យជ្រមុជទឹកឲ្យព្រះយេស៊ូវ

ម៉ាកុស ១៖៤-១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/IJ_lbWuscjE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/W_Z2V1UQ1n4

**គោលបំណង៖** ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ

**ខគម្ពីរចងចាំ៖** ម៉ាកុស ១៖១១ *"រួចឮសំឡេងពីលើមេឃថា ឯងជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្ត អញណាស់"*។

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

២.ខ្ញុំដឹងថា https://youtu.be/ywt-KvGIQcE

៣.ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ភ្លើងស្តុប»




១.កំណត់ទីតាំងនៅក្នុងថ្នាក់រៀន ដោយជ្រុងម្ខាងនៃថ្នាក់រៀន "ពណ៌ក្រហម" ហើយជ្រុងម្ខាងទៀតនៃថ្នាក់រៀន "ពណ៌បៃតង" ហើយនៅចំកណ្តាលថ្នាក់គឺ "ពណ៌លឿង" ។

២. ឲ្យកុមារឈរជាជួរនៅចំកណ្តាលថ្នាក់រៀន- នៅក្នុងពណ៌លឿង

៣.គ្រូនឹងស្រែកប្រាប់ថា "ពណ៌ក្រហម" "ពណ៌បៃតង" ឬក៏ "ពណ៌ លឿង" ហើយកុមារត្រូវតែរត់ទៅកាន់ កន្លែងដែលត្រឹមត្រូវ

៤. សូមពន្យល់កុមារថាគ្រប់ពណ៌ទាំងអស់ជាសញ្ញាដែលចង់ប្រាប់យើងថា ឈប់ ទៅ ឬក៏បន្ថយលឿន។ ក៏ដូចគ្នានេះដែល ព្រះបានប្រើសញ្ញា ដើម្បីបង្ហាញឲ្យយើងដឹងថា ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះ។

## ៤. ការណែនាំមេរៀន

តើលោកយ៉ូហានបាទីស្ទជាអ្នកណា?(កុមារឆ្លើយ) លោកយ៉ូហានបាទីស្ទជាអ្នករៀបចំផ្លូវសម្រាប់ព្រះយេស៊ូវ។ គាត់រស់នៅទីរហោស្ថាន ហើយស្លៀកសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ ស៊ីកណ្តូប និងទឹកឃ្មុំព្រៃ។ ចាំគាត់បានទេ? ថ្ងៃនេះ យើងនឹងរៀនអំពីព្រះយេស៊ូវបានជួបយ៉ូហានបាទីស្ទ ពេលគាត់មានអាយុ ៣០ ឆ្នាំ។ សូមរង់ចាំមើលថាមានអ្វីកើតឡើង!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះបានចាត់យ៉ូហានបាទីស្ទឲ្យទៅប្រកាសដល់មនុស្សអំពីការលើកលែងទោសពីអំពើបាប ដែលយើងបានប្រព្រឹត្តទាស់នឹងព្រះ។ នៅពេលដែលមនុស្សមកសារភាពអំពើបាបរបស់ខ្លួន ហើយបានទទួលការ

អភ័យទោស នោះយ៉ូហាននឹងធ្វើបុណ្យជ្រមុជទឹកដល់ពួកគេ។ ការធ្វើពិធីបុណ្យជ្រមុជគឺប្រៀបដូចជាសញ្ញាមួយអីចឹងដែរ។ វាបានប្រាប់មនុស្សអំពីអ្វីមួយដ៏សំខាន់។ ពិធីបុណ្យជ្រមុជទឹកគឺជាគំរូ ដែលព្រះយេ-ស៊ូវបានធ្វើសម្រាប់យើង ដោយការសុគតនៅលើឈើឆ្កាង។ តែមិនស្លាប់ទេ! ទ្រង់បានមានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងបានរស់ឡើងវិញ ពីអំពើបាបរបស់យើង ហើយរស់នៅសម្រាប់ទ្រង់។ នៅពេលយើងទទួលជឿ ហើយប្រែចិត្តពីអំពើបាប ហើយទុកចិត្តលើព្រះយេស៊ូវសម្រាប់ការអភ័យទោសនោះយើងអាចនៅជាមួយគ្នាជារៀងរហូតជាមួយព្រះ ហើយមានទំនាក់ទំនងជាមួយទ្រង់នៅលើផែនដីនេះ។ ពិធីបុណ្យជ្រមុជទឹកគឺជាគំរូមួយដើម្បីបង្ហាញអ្នកដទៃថាឥឡូវនេះអ្នកនឹងរស់នៅជាមួយព្រះជារៀងរហូត។

នៅគ្រានោះ ព្រះយេស៊ូវទ្រង់យាងមកពីភូមិណាសារ៉ែត ស្រុកកាលីឡេហើយបានឃើញលោកយូ៉ហានកំពុងតែធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សម្នា។ ហើយព្រះយេស៊ូវក៏ទទួលបុណ្យជ្រមុជទឹកពី យូ៉ហានបាទីស្ទនៅក្នុងទន្លេយ័រដាន់ដែរ។ ព្រះយេស៊ូវគឺល្អឥតខ្ចោះ។ ទ្រង់គឺមិនដែលធ្វើបាបនោះទេ។ តើទ្រង់គួតែធ្វើពិធីបុណ្យជ្រមុជទឹកដែរឬទេ? ទេ! ព្រះយេស៊ូវចង់ស្តាប់បង្គាប់ព្រះវរបិតាគ្រប់ផ្លូវទាំងអស់។ ទោះបីជាទ្រង់មិនចាំបាច់ទទួលបុណ្យជ្រមុជទឹកក៏ដោយ តែទ្រង់បានជ្រើសរើសធ្វើបុណ្យជ្រមុជទឹក ដើម្បីបង្ហាញអ្នករាល់គ្នាឲ្យឃើញថាទ្រង់កំពុងធ្វើតាមព្រះហើយស្តាប់បង្គាប់ព្រះវរបិតា។

តាមពិតនេះជាអ្វីដែលបានកើតឡើងនៅពេលដែលលោកយ៉ូហានធ្វើបុណ្យជ្រមុជឲ្យព្រះយេស៊ូវ ព្រះគម្ពីរ **ម៉ាកុស ១៖១០-១១** បាននិយាយថា “កាលកំពុងតែយាងឡើងពីទឹកមក ស្រាប់តែឃើញមេឃរបើក និងព្រះវិញ្ញាណ ចុះមកសណ្ឋិតលើទ្រង់ មានរូបដូចជាព្រាប រួចឮសំឡេងពីលើមេឃថា ឯងជាកូនស្ងួនភ្ងាអញជាទីពេញចិត្តអញណាស់” ។

តើអ្នកគិតថាសម្លេងនោះគឺជាសម្លេងរបស់នរណា? នោះគឺជា សម្លេងរបស់ព្រះវរបិតា។ តាមរយៈព្រះបន្ទូលព្រះបានប្រទានសញ្ញាដល់យើងរាល់គ្នាថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ទ្រង់។ ដូច្នេះ ពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវមានទីសំគាល់សំខាន់បីយ៉ាង។ តើអ្នកអាចរាប់សញ្ញាទាំងបីនោះបានដែរឬទេ? ទីមួយ (លើកម្រាមដៃមួយ)៖ វាជាសញ្ញានៃការស្តាប់បង្គាប់។ ទីពីរ (លើកម្រាមដៃពីរ)៖ វាជាសញ្ញាបញ្ជាក់ថាព្រះយេស៊ូវគឺជាអ្នកដើរតាមព្រះ។ ទីបី (លើកម្រាមដៃបី)៖ វាជាសញ្ញាបញ្ជាក់ថាព្រះយេស៊ូវជាបុត្រានៃព្រះ។

បន្ទាប់ពីព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ទ្រង់បានចាប់ផ្តើមកិច្ចការបម្រើរបស់ទ្រង់នៅលើផែនដី។ ទ្រង់បានបង្រៀនមនុស្សអំពីព្រះ ហើយបានធ្វើការអស្ចារ្យ ដើម្បីបង្ហាញដល់មនុស្សគ្រប់គ្នាថាទ្រង់ជានរណា។ ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះ!

## ៦. សំនួរពិភាក្សា

១. តើព្រះបានចាត់នរណាឲ្យមកផ្សាយអំពី ការអត់ទោសបាបមុនពេលព្រះយេស៊ូវយាងមក? *(យ៉ូហានបាទីស្ទ)*
២. តើពិធីបុណ្យជ្រមុជទឹកគឺជាអ្វី? *(វាគឺជាទីសញ្ញាមួយដែលយើងបង្ហាញដល់អ្នកដទៃជាសាធារណៈថាយើងជឿលើព្រះយេស៊ូវដែលបានសុគត ហើយបានរស់ឡើងវិញសម្រាប់យើង)*
៣. ហេតុអ្វីបានជាព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក? *(ដើម្បីស្តាប់បង្គាប់ព្រះ)*
៤. តើការជ្រមុជទឹករបស់ព្រះយេស៊ូវបង្ហាញសញ្ញាបីអ្វីខ្លះ? *(១៖សញ្ញានៃការស្តាប់បង្គាប់, ២៖ជាសញ្ញាបញ្ជាក់ថាព្រះយេស៊ូវគឺជាអ្នកដើរតាមព្រះ, ៣៖ ជាសញ្ញាថាព្រះយេស៊ូជាបុត្ររបស់ព្រះ)*

## ៧. ខគម្ពីរចងចាំ

**ម៉ាកុស ១៖១១** *រួចឮសំឡេងពីលើមេឃថា ឯងជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់”។*

## ៨. ហត្ថកម្ម «ព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក»

សម្ភារៈដែលត្រូវការ៖ ពែងក្រដាស ដងការ៉េម ក្រដាស ប៊ិក កន្ត្រៃ និងស្កុត



១. តុបតែងពែងរបស់អ្នកដោយ “រលកទឹក” ឬក៏ថ្ងៃរៀបលិចក៏បាន

២. សូមប្រុងប្រយ័ត្នក្នុងការបិតដងការ៉េមនៅបាតកែវ

៣. សូមផាត់ពណ៌រូបព្រះយេស៊ូវនិងសត្វព្រាប បន្ទាប់មកកាត់វាចេញមកក្រៅ

៤. បិតរូប “ព្រះយេស៊ូវ” នៅនឹងចុងដងការ៉េម

៥. សូមបិតដងការ៉េមមួយទៀតសម្រាប់ដាក់ព្រាប

៦. សត្វព្រាប និងព្រះយេស៊ូវយាងចុះទៅក្នុងពែង ហើយឡើងមកដូចជាសញ្ញានៃពិធីបុណ្យជ្រមុជទឹក។

## ៩. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកបានទទួលពិធីបុណ្យជ្រមុជទឹកហើយឬនៅ? ពិធីបុណ្យជ្រមុជទឹកគឺជាសញ្ញាជាសាធារណៈមួយសម្រាប់មនុស្សគ្រប់គ្នា ដែលបានតាំងចិត្តដើម្បីធ្វើជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ។ វាជាសញ្ញានៃសេចក្តីស្លាប់ចំពោះអំពើបាប និងជីវិតក្នុងព្រះគ្រីស្ទ។ ព្រះយេស៊ូវមិនចាំបាច់ទទួលការជ្រមុជទឹកទេ ដោយសារទ្រង់គ្មានអំពើបាបទេ។ ប៉ុន្តែ ព្រះអង្គបានទទួលបុណ្យជ្រមុជទឹតាមរយៈលោកយ៉ូហាន ដោយគោរពតាមព្រះជាម្ចាស់ - ដើម្បីបង្ហាញមនុស្សជាសាធារណៈថាទ្រង់កំពុងធ្វើតាមព្រះ។ ប្រសិនបើអ្នកបានទទួលបុណ្យជ្រមុជទឹក សូមសួរខ្លួនអ្នកថា តើអ្នកកំពុងរស់នៅក្នុងព្រះគ្រីស្ទឬទេ? ប្រសិនបើអ្នកមិនទាន់បានទទួលបុណ្យជ្រមុជទឹកទេ សូមពិចារណា ពីសេចក្តីប្រកាសជាសាធារណៈនេះ ដើម្បីបង្ហាញអ្នកដទៃថា អ្នកចង់រស់នៅក្នុងជីវិតមួយនៅក្នុងព្រះគ្រីស្ទ។